# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាប្រជុំបូជាចារ្យនៅភ្នំពេញថ្មី
# ថ្ងៃទី១៥ មីនា ២០១៧

អត្ថបទទី១៖ យរ ១៨,១៨-២០
ដំណឹងល្អ៖ មថ ២០,១៧-២៨

បងប្អូនជាទីស្រឡាញ់!

យើងកំពុងធ្វើដំណើរជាមួយព្រះយេស៊ូ ទៅទីក្រុងយេរូសាឡឹម ព្រះយេស៊ូកំពុងរៀបចំខ្លួនដើម្បីសោយទិវង្គតដោយសារជិតដល់ពេលវេលាហើយ។ យើងមានចំនុចខ្លះៗក្នុងគម្ពីរដែលណែនាំឲ្យយើងគិតថ្ងៃនេះ។

ទីមួយ ព្រះយេស៊ូដឹងថាត្រូវគេបញ្ជូនទៅក្នុងកណ្តាប់ដៃពួកនាយកបូជាចារ្យ និងពួកធម្មាចារ្យ តាមពិតនៅក្នុងគម្ពីរព្រះយេស៊ូបានប្រកាសបីដងអំពីថ្ងៃចុងក្រោយរបស់ព្រះអង្គ។ ព្រះយេស៊ូជាធម្មាចារ្យដែរ ព្រោះព្រះអង្គបានទៅទេសនាតាមធម្មសាលាផ្សេងៗតាំងពីអាយុ១២ឆ្នាំ បានពន្យល់ដល់ពួកនាយកបូជាចារ្យនិងពួកធម្មាចារ្យ គឺជាគ្នារបស់ព្រះយេស៊ូដែលចង់ចាប់ព្រះយេស៊ូ ចង់ក្បត់ព្រះយេស៊ូតែម្តង។

ទីពីរ នៅពេលព្រះយេស៊ូកំពុងនិយាយរឿងមួយ ដ៏ពិបាកមែនទែនសម្រាប់ជីវិតរបស់ព្រះអង្គ ដោយសារជីវិតរបស់ព្រះអង្គជិតអស់ហើយ។ ក្រុមគ្រីស្តទូតដែលជាមិត្តសម្លាញ់របស់គាត់ ដែលរស់នៅជាមួយព្រះអង្គទាំងថ្ងៃទាំងយប់ កំពុងលឺរឿងមួយដែលពិបាកចិត្តអស់សង្ឃឹម ផ្ទុយទៅវិញគេគិតអំពីរឿងគេ ធ្វើយ៉ាងណាដើម្បីឲ្យនៅខាងស្តាំនៅខាងឆ្វេង។ ទោះបីព្រះយេស៊ូនិយាយរឿងយ៉ាងសាហាវ អំពីរបៀបដែលគេសម្លាប់ព្រះយេស៊ូ ព្រះអង្គបានសួរគេថាអាចទទួលពែងនេះបានឬអត់? គេឆ្លើយថាគេអាចទទួលបាន ហាក់ដូចជាគេមិនយល់អំពីរឿងនេះ។ ដូច្នេះពេលយើងនឹកឃើញនេះ ធ្វើឲ្យយើងគិតថាព្រះយេស៊ូឯកោម្ល៉ាងដែរ ដោយសារទាំងខាងពួកនាយកបូជាចារ្យ ពួកធម្មាចារ្យ មានគម្រោងករចាប់ព្រះអង្គ ទាំងមិត្តសម្លាញ់របស់ព្រះអង្គ ពេលព្រះយេស៊ូអប់រំណែនាំពន្យល់បំភ្លឺក៏គេមិនយល់អ្វីសោះ មិនចាប់អារម្មណ៍អំពីអ្វីដែលកំពុងកើតឡើង។ ប៉ុន្តែជាឱកាសមួយសម្រាប់ព្រះយេស៊ូក្នុងការបំភ្លឺគេថែម ដើម្បីនិយាយអំពីឥរិយាបថ អំពីតួនាទី អំពីរបៀបរបស់យើងគឺជាអ្នក

បម្រើ ព្រះយេស៊ូមិនតែនិយាយសញ្ញាចុងក្រោយ គឺព្រះយេស៊ូលាងជើងឲ្យក្រុមគ្រីស្ទពិតមែន។

ដូច្នេះថ្ងៃនេះយើងអាចនឹកឃើញដល់ជីវិតរបស់យើងដែរ ព្រះយេស៊ូបានជ្រើសរើសយើងទៅជាមិត្តសម្លាញ់របស់ព្រះអង្គ ដើម្បីធ្វើដំណើរយ៉ាងជិតស្និតជាមួយព្រះអង្គ។ នៅក្នុងជីវិតរបស់យើង ប៉ុន្មានដងប៉ុន្មានសារយើងបានគិតអំពីរឿងផ្ទាល់ខ្លួននិងភ្លេចនឹកឃើញដល់ព្រះយេស៊ូ។ ប៉ុន្តែព្រះយេស៊ូ បានណែនាំឲ្យយើងយល់សារជាថ្មីអំពីជីវិតរបស់យើងជាអ្នកបម្រើ ព្រះយេស៊ូបានជ្រើសរើសយើងដើម្បីធ្វើជាមិត្តសម្លាញ់របស់ព្រះអង្គ ដើម្បីទៅជាអ្នកបម្រើ។ ក្នុងអភិបូជានេះយើងអរព្រះគុណព្រះជាម្ចាស់សសម្រាប់ភូមិភាគភ្នំពេញយើង សម្រាប់សកម្មភាពយុវជន គ្រូអប់រំជំនឿដល់បងប្អូន ដែលកំពុងរៀបចំទទួលអគ្គសញ្ញាជ្រមុជទឹក សកម្មភាពការិយាល័យសុខភាព ណែនាំឲ្យយើងអរព្រះគុណព្រះជាម្ចាស់សូមព្រះអង្គជួយយើង ដើម្បីឲ្យយើងបន្តធ្វើជាអ្នកបម្រើតាមរបៀបព្រះយេស៊ូ ដើម្បីឲ្យយើងម្នាក់ភ្ជាប់ជាមួយព្រះយេស៊ូ ដោយសារជាព្រះយេស៊ូដែលអាចបំភ្លឺណែនាំយើងជានិច្ច នៅក្នុងគ្រប់ការងារដែលយើងធ្វើ។ ពេលយើងមានអារម្មណ៍ថាឯកោគ្មានអ្នកយល់ចិត្តយើង ឲ្យយើងនឹកឃើញព្រះយេស៊ូ ដោយសារព្រះយេស៊ូមិនសូវមានអ្នកណាយល់អំពីព្រះអង្គ ប៉ុន្តែព្រះយេស៊ូបានសោយទិវង្គត់ដើម្បីឲ្យយើងមានជីវិត។

ដូច្នេះយើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានសេចក្តីសង្ឃឹមឲ្យយើងជានិច្ច ដើម្បីធ្វើជាមិត្តសម្លាញ់ ដើម្បីធ្វើជាគ្រីស្តទូតដែលជាអ្នកបម្រើនិងប្រកាសដំណឹងល្អដូចព្រះយេស៊ូ។ អាម៉ែន។